

United Nations | UN-WATER | unesco

# ទឹកសម្រាប់ទាំងអស់គ្នា

## សិទ្ធិ និងឱកាសស្មើគ្នា

របាយការណ៍អង្គការសហប្រជាជាតិស្តីពីការអភិវឌ្ឍទឹកពិភពលោកឆ្នាំ២០២៦

**សេចក្តីសង្ខេបពិស្តារ**

ការទទួលបានសេវាទឹកស្អាត និងអនាម័យប្រកបដោយសុវត្ថិភាព និងមានតម្លៃសមរម្យ ព្រមទាំងការផ្គត់ផ្គង់ទឹកឱ្យបានគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ផ្សេងៗទៀតមានសារៈសំខាន់នៅក្នុងការបំពេញតម្រូវការចាំបាច់ និងបំណងប្រាថ្នាជាមូលដ្ឋានរបស់ប្រជាជនទាំងអស់។ នៅពេលមានកង្វះខាតការទទួលបានសេវាទឹកស្អាត និងអនាម័យ (WASH) ជារឿយៗ ស្ត្រី និងក្មេងស្រីមានទំនួលខុសត្រូវខ្ពស់ជាងគេនៅក្នុងការផ្គត់ផ្គង់ទឹកសម្រាប់ប្រើប្រាស់នៅក្នុងគ្រួសារ។

ជាទូទៅស្ត្រីមិនសូវមានតំណាងនៅក្នុងការគ្រប់គ្រង និងការគ្រប់គ្រងការផ្គត់ផ្គង់ទឹក រួមទាំងការផ្តល់ហិរញ្ញប្បទាន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងទឹកផងដែរ។ ស្ថានភាពនេះអាចរារាំងដល់ការទទួលបានធនធានទឹក និងការបែងចែកផលប្រយោជន៍ឱ្យបានស្មើៗគ្នា ដែលកត្តានេះជាការគំរាមកំហែងដល់សុខភាព ជីវភាព និងសន្តិសុខស្បៀងអាហាររបស់ស្ត្រីផងដែរ។

## សមភាពយេនឌ័រគឺជាមាគ៌ាដ៏សំខាន់ឆ្ពោះទៅរកការទទួលបាន និងការប្រើប្រាស់ទឹកដោយស្មើភាព និងយុត្តិធម៌

របាយការណ៍ដែលមានចំណងជើងថាទឹកសម្រាប់ទាំងអស់គ្នា៖ សិទ្ធិ និងឱកាសស្មើគ្នា នេះផ្តល់នូវសេចក្តីសង្ខេបពិស្តារ និងផ្អែកលើភស្តុតាងដែលបង្ហាញអំពីទំនាក់ទំនងរវាងនិងដំណើរឆ្ពោះទៅរកសមភាពទឹក និងយេនឌ័រ។ របាយការណ៍នេះរៀបរាប់អំពីរបៀបប្រែក្លាយក្របខណ្ឌបទដ្ឋាន និងគោលនយោបាយ ឱ្យទៅជាការវិភាគបញ្ហា គោលការណ៍ស្តីពីការរៀបចំកម្មវិធី និងការអនុវត្តសកម្មភាពជាយុទ្ធសាស្ត្រនៅក្នុងវិស័យទឹក។ ដោយយល់ថានេះគឺជាការប្រើប្រាស់សិទ្ធិស្មើៗគ្នា ការទទួលខុសត្រូវ និងឱកាសស្មើៗគ្នាសម្រាប់មនុស្សទាំងអស់ ដោយមិនគិតអំពីភេទ និង/ឬយេនឌ័រ។

## ទឹកពិសា និងអនាម័យនៅតាមទីលំនៅរបស់មនុស្ស

គិតត្រឹមឆ្នាំ២០២៤ មានមនុស្សចំនួន ២.១ ប៊ីលាននាក់ នៅតែជួបប្រទះកង្វះខាត ទឹកពិសាដែលមានការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ចំណែកមនុស្សចំនួន ៣.៤ ប៊ីលាននាក់ផ្សេងទៀត នៅតែមានកង្វះខាតសេវាអនាម័យដែលមានការគ្រប់គ្រងប្រកបដោយសុវត្ថិភាព និងចំនួន ១.៧ ប៊ីលាននាក់ ខ្វះខាតសេវាអនាម័យជាមូលដ្ឋាននៅតាមលំនៅដ្ឋាន។

ភាគច្រើន ស្ត្រី និងក្មេងស្រីគឺជាអ្នកទទួលខុសត្រូវនៅក្នុងការទៅដងទឹកប្រើប្រាស់ ដែលធ្វើឱ្យពួកគាត់ប្រឈមនឹងការលំបាកផ្នែករាងកាយ និងមានហានិភ័យចំពោះសុវត្ថិភាព ជាពិសេសនៅតំបន់ដាច់ស្រយាល ឬតំបន់ដែលគ្មានសុវត្ថិភាព។ ការយួរទឹកអាចបណ្តាលឱ្យរាងកាយខំប្រឹងប្រើកម្លាំងខ្លាំង និងបង្កឱ្យមានរបួស ហើយស្ត្រី និងក្មេងស្រីអាចប្រឈមមុខនឹងអំពើហិង្សាផ្អែកលើយេនឌ័រ។ កង្វះឯកជនភាព និងសុវត្ថិភាពដោយសារតែបរិក្ខារអនាម័យមិនល្អក៏ប៉ះពាល់ដល់ស្ត្រី និងក្មេងស្រីខ្លាំងជាងគេផងដែរ។ នៅពេលទឹកគ្មានសុវត្ថិភាព ឬគ្មានស្ថិរភាព ការងារប្រចាំថ្ងៃមិនទទួលបានប្រាក់នៅក្នុងការគ្រប់គ្រង ការកំណត់របប និងការកំណត់អាទិភាពលើការប្រើប្រាស់ទឹក ព្រមទាំងការងារថែទាំគ្រួសារអាចបណ្តាលឱ្យគ្រួសារមានជំងឺ។

សិទ្ធិមនុស្សនៅក្នុងការទទួលបានទឹក និងសេវាអនាម័យ ផ្តល់សិទ្ធិឱ្យមនុស្សទាំងអស់អាចទទួលបានទឹកពិសាដែលមានអនាម័យ និងមានសុវត្ថិភាព និងសេវាអនាម័យគ្រប់គ្រាន់ ដែលមានការផ្តល់ជូនស្មើៗគ្នា និងដោយគ្មានការរើសអើង។ ការបំពេញសិទ្ធិទាំងនេះ តម្រូវឱ្យមានការលុបបំបាត់ឧបសគ្គទាំងអស់នៅក្នុងការទទួលបានទឹកពិសាដែលមានសុវត្ថិភាព និងសេវាអនាម័យ ជាពិសេសសម្រាប់ប្រជាជនដែលជួបការលំបាកខ្លាំង។ វិធានការនេះក៏រាប់បញ្ចូលទាំងការលុបបំបាត់ឧបសគ្គចំពោះការចូលរួមដោយស្មើភាពពីបុរស និងស្ត្រីនៅក្នុងការគ្រប់គ្រងទឹកផងដែរ។

ទោះជាយ៉ាងនេះក្តី វិសមភាពយេនឌ័រនៅក្នុងការទទួលបានការចូលរួម និងការដឹកនាំរបស់ស្ត្រីនៅតែមានកម្រិតខ្ពស់នៅឡើយ ជាពិសេសនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម។ វិសមភាពយេនឌ័រនៅក្នុងការទទួលបានសេវាទឹកស្អាត និងអនាម័យ (WASH) កើតឡើងជាផ្នែកមួយនៃគំរូវិសមភាពផ្សេងៗទៀត និងការរើសអើងនៅក្នុងសង្គម។

ការកាន់កាប់ដីធ្លីដោយសុវត្ថិភាព និងសិទ្ធិមានលំនៅឋានជារឿយៗគឺជាបុរេលក្ខខណ្ឌសម្រាប់ការទទួលបានសេវាទឹកស្អាត និងអនាម័យក្នុងទីក្រុង។ លំនៅឋានដែលមានស្ថានភាពមិនល្អ ការកាន់កាប់ដីធ្លីដែលគ្មានសុវត្ថិភាព និងការរើសអើងនៅក្នុងសិទ្ធិលំនៅឋានអាចប៉ះពាល់ដល់ស្ត្រីនៅក្នុងកម្រិតខ្ពស់ជាងគេ។ តាមរយៈកម្មសិទ្ធិស្របច្បាប់ ឬការកាន់កាប់ដោយមានការទទួលស្គាល់ ពលរដ្ឋអាចមានលទ្ធភាពទាមទារសេវាដែលល្អប្រសើរជាងមុន ដែលក្នុងនោះមានទាំងទឹក និងសេវាអនាម័យផងដែរ។

ការទទួលបានសេវាទឹកស្អាត និងអនាម័យប្រកបដោយសុវត្ថិភាពនៅតាមសាលារៀនរួមចំណែកលើកកម្ពស់សុខភាព បង្កើនអត្រាចូលរៀនកាន់តែខ្ពស់ និងចុងក្រោយធ្វើឱ្យលទ្ធផល អប់រំកាន់តែល្អប្រសើរ។ នៅតាមមូលដ្ឋានថែទាំសុខភាព បង្គន់អនាម័យដែលបែងចែកតាមភេទ និងមានការថែទាំបានល្អប្រើ គួរផ្តល់ជូនសម្រាប់បុគ្គលិក និងអ្នកជំងឺ ហើយគួរមានសម្ភារបរិក្ខារសម្រាប់រក្សាអនាម័យពេលមករដូវ។

> **វិសមភាពយេនឌ័រនៅក្នុងការទទួលបានសេវាទឹកស្អាត និងអនាម័យ កើតឡើងជាផ្នែកមួយនៃគំរូវិសមភាពផ្សេងៗទៀត និងការរើសអើងនៅក្នុងសង្គម**

សហគមន៍សេវាទឹកស្អាត និងអនាម័យ តែងតែអំពាវនាវឱ្យមានដំណោះស្រាយ "តម្លៃទាប" ដោយពុំបានស្រាវជ្រាវឱ្យដឹងអំពីលទ្ធភាពរបស់គ្រួសារនៅក្នុងការបង់ប្រាក់ចំណាយឱកាសនៃការទូទាត់ទាំងនេះ ឬអ្នកដែលចំណាយប្រាក់ឡើយ។ វិធីសាស្ត្រសហគមន៍សេវាទឹកស្អាត និងអនាម័យទាំងនេះមួយចំនួន អាចមានតម្លៃទាបនៅក្នុងផ្នែកខ្លះ ដោយសារតែពុំមានការចំណាយប្រាក់ទៅលើកម្លាំងពលកម្មដែលពាក់ព័ន្ធនឹងការអនុវត្ត និងការថែទាំ។

ការកាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងសេវាទឹកស្អាត និងអនាម័យតម្រូវឱ្យ មានកិច្ចអន្តរាគមន៍ហួសពីដំណោះស្រាយផ្នែកបច្ចេកទេស រហូតទៅដល់កិច្ចអន្តរាគមន៍ដែលដោះស្រាយបញ្ហាវិសមភាពរចនាសម្ព័ន្ធ និងសង្គម។ ឧទាហរណ៍បង្ហាញថា នៅពេល ស្ត្រីត្រូវបានរៀបចំឱ្យមានការចូលរួមដើម្បីលើកទឹកចិត្តដល់ភាពជាអ្នកដឹកនាំ និងការបញ្ចេញសំឡេងដែលផ្ទុយពីការគ្រាន់តែធ្វើដើម្បីបង្គ្រប់កិច្ច ស្ត្រីគឺជាភ្នាក់ងារផ្លាស់ប្តូរដ៏សកម្មដើម្បីធានាឱ្យមានសមភាពយេនឌ័រ និងសមភាពនៅក្នុងការទទួលបានសេវាទឹកស្អាត និងអនាម័យ។

## អាហារ និង កសិកម្ម

ការទទួលបាន និងការគ្រប់គ្រងទឹកក្នុងវិស័យកសិកម្មអាចមានការរើសអើងយេនឌ័រនៅក្នុងកម្រិតមួយដ៏ខ្ពស់។ ដោយសារតែវប្បធម៌ប្រពៃណី និងក្របខណ្ឌច្បាប់ក្នុងការកាន់កាប់ដី និងទឹក ស្ត្រីនៅតាមតំបន់ជនបទអាចជួបប្រទះឧបសគ្គនៅក្នុងការទទួលបាន និងការគ្រប់គ្រងទឹកសម្រាប់ប្រព័ន្ធធារាសាស្ត្រ ការចិញ្ចឹមសត្វ វារីវប្បកម្ម និងការប្រើប្រាស់ក្នុងគ្រួសារ ច្រើនជាងបុរស។ ទោះនៅពេលស្ត្រីបានចូលរួមនៅក្នុងការគ្រប់គ្រងទឹកសម្រាប់វិស័យកសិកម្ម យ៉ាងណាក្តី ក៏ជារឿយៗ តួនាទីរបស់ស្ត្រីមិនត្រូវបានទទួលស្គាល់ឡើយ ដែលកត្តានេះធ្វើឱ្យ ការបែងចែកសិទ្ធិអំណាច និងសក្តានុពលសេដ្ឋកិច្ចសម្រាប់ស្ត្រីនៅមានកម្រិតនៅឡើយ។

ស្ត្រីកាន់តែមានសុវត្ថិភាពនៅក្នុងការកាន់កាប់ទឹក នៅពេលដែលអន្តរាគមន៍ប្រើប្រាស់វិធីសាស្ត្រឆ្ពោះទៅរកសមភាពយេនឌ័រដើម្បីជម្នះនឹងទំនៀមទម្លាប់មិនផ្តល់តម្លៃចំពោះស្ត្រី។ ទោះជាយ៉ាងនេះក្តី ភាពជាម្ចាស់កម្មសិទ្ធិជាផ្លូវការលើដីធ្លី និងធនធានទឹកមិនអាចធានាឱ្យមានការគ្រប់គ្រងឡើយ ជាពិសេសនៅពេលដែលសិទ្ធិប្រើប្រាស់ (សិទ្ធិទទួលបាន និងការទាញយក) មានលក្ខណៈខុសពីសិទ្ធិគ្រប់គ្រង (សិទ្ធិចាត់ចែង សិទ្ធិបដិសេធ សិទ្ធិប្រគល់ទៅឱ្យអ្នកដទៃ)។

វិសមភាពយេនឌ័រក្នុងការទទួលបានដីធ្លី និងគ្រប់គ្រងធនធានទឹកក្នុងវិស័យកសិកម្មអាចប៉ះពាល់ជាអវិជ្ជមានចំពោះការទទួលបានការអប់រំរបស់ក្មេងស្រី ជីវភាព និងការផ្តល់ភាពអង់អាចដល់ស្ត្រី ព្រមទាំងសុខភាព និងអាហារូបត្ថម្ភក្នុងគ្រួសារផងដែរ។ វិសមភាពទាំងនេះធ្វើឱ្យស្ត្រីកាន់តែងាយទទួលរងគ្រោះពីបញ្ហាអសន្តិសុខស្បៀងកាន់តែខ្លាំងថែមមួយកម្រិតទៀត។

ការធ្វើចំណាកស្រុកកំពុងតែផ្លាស់ប្តូរតួនាទីយេនឌ័រនៅក្នុងវិស័យកសិកម្ម។ នៅក្នុងប្រទេសជាច្រើន គ្រួសារដែលមានស្ត្រីជាមេគ្រួសារកាន់តែមានចំនួនកើនឡើងដោយសារបុរសបានធ្វើចំណាកស្រុក។

ផលប៉ះពាល់នៃការធ្វើចំណាកស្រុកទៅលើការសម្រេចចិត្តរបស់ស្ត្រីក្នុងការបង្កបង្កើនផលកសិកម្ម ការគ្រប់គ្រងប្រាក់ចំណូល សមាជិកភាពក្រុម និងបន្ទុកការងារ គឺអាស្រ័យទៅលើកត្តាមួយចំនួនដូចជា កម្មសិទ្ធិដីធ្លីក្នុងគ្រួសារ តួនាទីរបស់ស្ត្រីក្នុងគ្រួសារ និងថាតើគ្រួសារទទួលបានប្រាក់ដែលបានផ្ញើមកដែរឬទេ។

ការលើកកម្ពស់សិទ្ធិប្រើប្រាស់ប្រព័ន្ធធារាសាស្ត្ររបស់ស្ត្រីអាចផ្តល់អត្ថប្រយោជន៍ហួសពីការបង្កបង្កើនផលកសិកម្ម។ បច្ចេកវិទ្យាប្រព័ន្ធធារាសាស្ត្រអាចកាត់បន្ថយបន្ទុកកម្លាំងពលកម្ម និងពេលវេលា។ នៅពេលរៀបចំជាសេវាទឹកសម្រាប់ការប្រើប្រាស់ច្រើនបែប បច្ចេកវិទ្យានេះក៏អាចគាំទ្រដល់តម្រូវការក្នុងគ្រួសារ និងតម្រូវការផលិតកម្មផ្សេងៗទៀតផងដែរ។ ការលើកកម្ពស់វិធានការរួមតាមរយៈការពង្រឹងក្រុមស្ត្រី និងអង្គការតាមមូលដ្ឋានអាចពង្រីកវិសាលភាពនៃអត្ថប្រយោជន៍ទាំងនេះ។

## ឧស្សាហកម្ម ក្រុមហ៊ុនអាជីវកម្ម និងថាមពល

វិស័យទឹកកំពុងជួបការលំបាកក្នុងការទាក់ទាញ បណ្តុះបណ្តាល និងរក្សាធនធានមនុស្សនៅក្នុងបណ្តាប្រទេសជាច្រើនក្នុងពិភពលោក ដែលក្នុងនោះមានទាំងការចូលរួមរបស់ស្ត្រីនៅក្នុងមុខតំណែងគ្រប់គ្រង និងដឹកនាំផងដែរ។ ទោះបីក្រុមហ៊ុនផ្គត់ផ្គង់ទឹកមួយចំនួនមានបុគ្គលិកស្ត្រីចំនួនជិត 40% យ៉ាងណាក្តី ក៏ប៉ុន្តែមានអង្គភាព និងទីតាំងមួយចំនួនគ្មានបុគ្គលិកស្ត្រីឡើយ។ ការសម្រេចបានសមភាពយេនឌ័រនៅក្នុងការងារវិស័យទឹកស្អាត និងអនាម័យ អាចសម្រេចទៅបាន ជាពិសេសនៅក្នុងមុខតំណែងមួយចំនួនដូចជាការងារអនាម័យ និងសុខភាពសហគមន៍ជាដើម។

ការទទួលបានថាមពលមានសារៈសំខាន់សម្រាប់ការប្រើប្រាស់ទឹកតាមផ្ទះ និងនៅក្នុងការធ្វើកសិកម្ម ជាពិសេសនៅកន្លែងដែលត្រូវការបូមទឹក។ ទោះបីជាស្ត្រីធ្លាប់ប្រើប្រាស់ស្នប់សប់ទឹកដោយដៃបែបប្រពៃណីយ៉ាងណាក្តី ប៉ុន្តែការផ្លាស់ប្តូរទៅប្រើប្រាស់ប្រព័ន្ធដើរដោយតន្ទនៈ និងថាមពលព្រះអាទិត្យជួយដល់ការសន្សំសំចៃពេលវេលា។

ទោះបីយ៉ាងណា បរិក្ខារអនាម័យនៅមិនទាន់បានផ្តល់ជូនបុរស និងស្ត្រីដាច់ដោយឡែកពីគ្នានៅឡើយទេ។ ជាទូទៅបរិក្ខារទាំងនោះមិនសមស្របសម្រាប់តម្រូវការមួយចំនួនរបស់ស្ត្រីឡើយ ដូចជាបរិក្ខារសម្រាប់ស្ត្រីកំពុងមករដូវ ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន ជាដើម។ ប្រទេស និងអង្គភាពជាច្រើនបានប្រើប្រាស់គោលការណ៍ណែនាំស្តីពី ចំនួនបង្គន់សម្រាប់កម្មករនិយោជិត ដោយធ្វើការបែងចែកតម្រូវការសម្រាប់បុរស និងស្ត្រីដាច់ដោយឡែកពីគ្នា ទោះបីជាគោលការណ៍ណែនាំទាំងនេះអាចមានការលំបាកក្នុងការអនុវត្តសម្រាប់សហគ្រាសតូចៗយ៉ាងណាក្តី។

ក្រុមហ៊ុនអាជីវកម្ម និងរោងចក្រឧស្សាហកម្មអាចលើកកម្ពស់សមភាពយេនឌ័រនៅក្នុងការប្រើប្រាស់ទឹកតាមរយៈការគាំទ្រយ៉ាងមុតមាំចំពោះគោលនយោបាយ និងការអនុវត្តដែលផ្អែកលើគោលការណ៍ផ្តោតលើចីរភាព សមធម៌ និងបរិយាបន្ន។ ក្រុមហ៊ុននានាក៏អាចចាប់ផ្តើមធ្វើការបណ្តុះបណ្តាលលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងធ្វើការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធទឹកក្នុងសហគមន៍ផងដែរ។ ដោយមានចំណែកមួយនៅក្នុងទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន រោងចក្រឧស្សាហកម្មអាចផ្តល់មូលនិធិសម្រាប់គំនិតផ្តួចផ្តើមដែលគាំទ្រដល់ការទទួលបានទឹក ការអប់រំ និងការលើកកម្ពស់ជីវភាពរបស់ស្ត្រីផងដែរ។ ការផ្តល់ជូននេះអាចមានការផ្តល់អាហារូបករណ៍សម្រាប់ស្ត្រីដែលកំពុងសិក្សាអំពីការគ្រប់គ្រងទឹក ឬការវិនិយោគលើសហគ្រាសទឹកដែលមានស្ត្រីជាអ្នកដឹកនាំ។

## ទឹកស្អាត និងអនាម័យនៅកន្លែងធ្វើការ ត្រូវបានដឹងថាជួយបង្កើនផលិតភាព និងសុខភាពធនធានមនុស្ស

សវនកម្មយេនឌ័រអាចជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ការវាយតម្លៃជាប្រព័ន្ធទៅលើវិសាលភាពដែលសមភាពយេនឌ័រមាននៅក្នុងអង្គភាព កម្មវិធី និងវិស័យនានា រួមទាំងនៅក្នុងវិស័យឧស្សាហកម្ម ធុរកិច្ច និងថាមពលផងដែរ។ សវនកម្មទាំងនេះត្រួតពិនិត្យទៅលើគោលនយោបាយការអនុវត្តនៅកន្លែងធ្វើការ និងរចនាសម្ព័ន្ធដឹកនាំ ដើម្បីកំណត់រកវិសមភាពដែលអាចដាក់កម្រិតលើការចូលរួមរបស់ស្ត្រី ឬផ្នែកដែលស្ត្រីអាចទទួលបានប្រយោជន៍ពីឱកាស និងធនធានផ្សេងៗ។

# ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយជលាឧតុនិយម

ការប្រែប្រួលអាកាសធាតុកំពុងបង្កការគំរាមកំហែងកាន់តែខ្លាំងចំពោះសុខុមាលភាពមនុស្សដោយបង្កផលប៉ះពាល់ទៅលើសន្តិសុខទឹក និងស្បៀង សុខភាពសាធារណៈ ស្ថិរភាពសេដ្ឋកិច្ច និងបរិស្ថាន។ ការកើតឡើងកាន់តែខ្លាំង និងវិសាលភាពកាន់តែធំនៃមុខសញ្ញាគ្រោះថ្នាក់ជលាឧតុនិយម បង្ហាញថា ចាំបាច់ត្រូវមានបន្ទាន់នូវវិធីសាស្ត្រដែលមានភាពបត់បែន មានភាពធន់ និងមានលក្ខណៈរួមបញ្ចូលគ្នាដើម្បីអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ (DRM)។

យេនឌ័រ គឺជាកត្តាកំណត់រចនាសម្ព័ន្ធគន្លឹះនៃភាពងាយរងគ្រោះចំពោះគ្រោះមហន្តរាយ។ ការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលអភិវឌ្ឍន៍អាចអាស្រ័យលើការដាក់បញ្ចូលការពិចារណាអំពីយេនឌ័រទៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងភាពធន់នឹងគ្រោះមហន្តរាយ។

គ្រោះមហន្តរាយជលាឧតុនិយមអាចប៉ះពាល់ខ្លាំងចំពោះស្ត្រី ក្មេងស្រី និងមនុស្សចម្រុះភេទ ដោយសារតែវិសមភាពជាប្រព័ន្ធនៅក្នុងការទទួលបានធនធាន ការធ្វើសេចក្តីសម្រេចចិត្ត និងសេវាផ្សេងៗ។ ស្ត្រីអាចប្រឈមនឹងហានិភ័យកាន់តែខ្ពស់ចំពោះជីវភាព សិទ្ធិ សុវត្ថិភាព និងសុខភាព (ជាពិសេសសុខភាព និងអនាម័យពេលមករដូវ)។ សេវាជលាឧតុនិយមដូចជាប្រព័ន្ធជូនដំណឹងជាមុន ដែលដឹងអំពីវិសមភាព មានការឆ្លើយតបនៅក្នុងកិច្ចអន្តរាគមន៍ និងមានលក្ខណៈបរិយាបន្ននៅក្នុងការតំណាង អាចជួយធានាថា មនុស្សគ្រប់ភេទទាំងអស់មានការចូលរួម ទទួលបានការការពារ និងត្រូវបានផ្តល់ភាពអង់អាច។

ទោះបីការបញ្ជ្រាបយេនឌ័រ និងយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ (DRM) ត្រូវបានគាំទ្រយ៉ាងទូលំទូលាយយ៉ាងណាក្តី ហើយបច្ចុប្បន្នមានការយល់ដឹងកាន់តែច្រើនអំពីការពិចារណាពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ (DRM) យ៉ាណាក្តី ក៏ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានកម្រិតនៅឡើយ ដែលមួយផ្នែកកើតឡើងដោយសារការណែនាំមិនគ្រប់គ្រាន់។ កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយដែលមានការពិចារណាលើយេនឌ័រអាចជួយកសាងហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់ និងគោលនយោបាយមានលក្ខណៈបរិយាបន្ន ដែលអាចកាត់បន្ថយហានិភ័យរយៈពេលវែង និងលើកកម្ពស់ការគ្រប់គ្រងធនធានទឹកលក្ខណៈរួមបញ្ចូលគ្នាប្រកបដោយចីរភាព។

កិច្ចអន្តរាគមន៍ប្រកបដោយសមធម៌ និងកែសម្រួលតាមតម្រូវការអាចជួយការពារប្រជាជនងាយរងគ្រោះ និងលើកកម្ពស់សិទ្ធិមនុស្ស ដោយកាត់បន្ថយការខូចខាតសង្គម និងសេដ្ឋកិច្ចភ្លាមៗដែលបង្កឡើងដោយគ្រោះមហន្តរាយ។ ការស្វែងយល់អំពីថាតើ យេនឌ័រប៉ះពាល់យ៉ាងដូចម្តេចខ្លះចំពោះកម្រិតប៉ះពាល់ ការទទួលបានធនធាន តម្រូវការ និងការឆ្លើយតបចំពោះគ្រោះមហន្តរាយជលាឧតុនិយមកសាងមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំអន្តរាគមន៍យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ (DRM) និងសម្រាប់ការបង្កើតយុទ្ធសាស្ត្រសម្របខ្លួនទៅនឹងអាកាសធាតុចំគោលដៅ ប្រកបដោយសមធម៌ និងមានលក្ខណៈបរិយាបន្ន។

# ប្រព័ន្ធអេកូឡូស៊ី

កត្តាចម្បងដែលបណ្តាលឱ្យមានការសឹករេចរឹលប្រព័ន្ធអេកូឡូស៊ីទឹក និងការបាត់បង់ជីវៈចម្រុះ រួមមាន ការប្រែប្រួលអាកាសធាតុ ការប្រែប្រួលការប្រើប្រាស់ដីធ្លី និងការបំពុលបរិស្ថាន។ ការវិភាគលើទំនាក់ទំនងដ៏ស្មុគស្មាញទាំងនេះតាមរយៈការឆ្លុះបញ្ចាំអំពីសមភាពយេនឌ័រអាចជួយឱ្យកាន់តែយល់ច្បាស់អំពីផលប៉ះពាល់ជាក់លាក់ និងដែលជារឿយៗមានលក្ខណៈមិនស្មើគ្នាទៅលើស្ត្រី និងបុរស ព្រមទាំងគូសរំលេចនូវតួនាទីផ្សេងៗរបស់បុរស និងស្ត្រីនៅក្នុងការគ្រប់គ្រងទឹក និងប្រព័ន្ធអេកូឡូស៊ី ខណៈរួមចំណែកនៅក្នុងការលើកកម្ពស់សមភាពយេនឌ័រ។

នៅក្នុងវប្បធម៌ និងសហគមន៍នានា ស្ត្រីបានចូលរួមនៅក្នុងការការពារ និងគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ដោយធ្វើការអភិវឌ្ឍ និងផ្ទេរចំណេះដឹងក្នុងមូលដ្ឋាន និងបែបប្រពៃណី ពីមួយជំនាន់ទៅមួយជំនាន់។ ការធានាថាស្ត្រីអាចទទួលបានសេវាប្រព័ន្ធអេកូឡូស៊ីស្មើៗគ្នា និងចូលរួមនៅក្នុងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីអាចជួយកាត់បន្ថយវិសមភាពយេនឌ័រដែលរួមចំណែកកសាងសហគមន៍មួយដែលមានសមភាព និងភាពធន់ជាងមុន។

នៅកម្រិតសហគមន៍ ជវភាពសង្គម និងនយោបាយមានតួនាទីដ៏សំខាន់នៅក្នុងការកំណត់ការប្រើប្រាស់ និងការទទួលបានធនធាន ព្រមទាំងអត្ថប្រយោជន៍សេដ្ឋកិច្ចនៃធនធានទាំងនោះ ជាពិសេសនៅពេលការទទួលបានដី ឬធនធានរួមត្រូវបានរឹតត្បិតដោយការរើសអើងផ្អែកលើយេនឌ័រ ដែលចាក់ឫសគល់នៅក្នុងទំនៀមទម្លាប់សង្គម-វប្បធម៌។

ការដាក់បញ្ចូលចំណេះដឹងបែបប្រពៃណី ចំណេះដឹងជនជាតិដើមភាគតិច និងចំណេះដឹងតាមមូលដ្ឋានទៅក្នុងការគ្រប់គ្រងទឹក និងប្រព័ន្ធអេកូឡូស៊ី មានសារៈសំខាន់ខ្លាំង សម្រាប់ថ្នាក់ដឹកនាំក្នុងមូលដ្ឋាន ព្រមទាំងវិធីសាស្ត្រស្តារ និងគ្រប់គ្រងទឹក និងប្រព័ន្ធអេកូឡូស៊ីតាម សហគមន៍។

ការប្រើប្រាស់វិធីសាស្ត្រយេនឌ័រអាចលើកកម្ពស់យុទ្ធសាស្ត្រដែលកាន់តែមានលក្ខណៈបរិយាបន្ន មានភាពធន់ និងកាន់តែមានភាពច្នៃប្រឌិត ដើម្បីគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីពាក់ព័ន្ធនឹងទឹកតាមរយៈការដោះស្រាយបញ្ហាជាក់ស្តែងរបស់ស្ត្រី និងក្មេងស្រី។ ទោះបីស្ត្រីអាចនឹងទទួលបន្ទុកធ្ងន់ធ្ងរពីការសឹករេចរឹលប្រព័ន្ធអេកូឡូស៊ី ដោយសារតែតួនាទីកំណត់តាមយេនឌ័រ ការទទួលបានទឹក និងធនធានធម្មជាតិនៅមានកម្រិត និងវិសមភាពសង្គមយ៉ាងណាក្តី ប៉ុន្តែស្ត្រីបំពេញតួនាទីដ៏សកម្មក្នុងនាមជាប្រជាសហគមន៍ និងជាអ្នកដឹកនាំសហគមន៍ ដែលមានចំណេះដឹងសំខាន់ៗ ដែលអាចរួមចំណែកនៅក្នុងការកសាងសហគមន៍ដែលមានភាពធន់ មានផលិតភាព និងប្រកបដោយចីរភាព។

# ទស្សនវិស័យក្នុងតំបន់

## អនុតំបន់សាហារ៉ាអាហ្វ្រិក

ឧបសគ្គខាងសេដ្ឋកិច្ចសង្គម ទំនៀមទម្លាប់ប្រពៃណី និងច្បាប់កេរ្តិ៍តំណែល ដែលអនុគ្រោះដល់បុរស ជារឿយៗ ធ្វើឱ្យវិសមភាពយេនឌ័រកាន់តែធ្ងន់ធ្ងរឡើងក្នុងការទទួលបានទឹកនៅទូទាំងអនុតំបន់សាហារ៉ា អាហ្វ្រិក។ នេះអាចនាំឱ្យមានការចូលរួមក្នុងយេនឌ័រ មិនមានភាពស្មើគ្នា ព្រមទាំងផលប៉ះពាល់ពីការ អភិវឌ្ឍន៍ទាក់ទងនឹងទឹក និងបញ្ហាប្រឈមនឹងអាកាសធាតុ។ ការពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ច អាចជួយឱ្យសម្រេចបាននូវសិទ្ធិ ទទួលបាន ធនធានទឹកប្រកបដោយសមធម៌ ដោយទទួលស្គាល់តួនាទី ដ៏សំខាន់ដែលស្ត្រីដើរតួក្នុងការគ្រប់គ្រងទឹក និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត នឹងការបញ្ចូលចំណេះដឹង ជនជាតិដើមភាគតិច។

គំនិតផ្តួចផ្តើមក្នុងការកសាងសមត្ថភាពក៏អាចជួយផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងយុវជនតាមរយៈការអប់រំ និងការអភិវឌ្ឍន៍វិជ្ជាជីវៈ ដែលជួយលើកកម្ពស់សមភាពយេនឌ័រក្នុងវិជ្ជាជីវៈទាក់ទងនឹងទឹក។ ការផ្សព្វផ្សាយ ការត្រួតពិនិត្យ និងការវាយតម្លៃផ្អែកលើយេនឌ័រអាចនាំមកនូវការផ្លាស់ប្តូរអាកប្បកិរិយាក្នុងការចូលរួម និងការប្រើប្រាស់ទឹកនៅក្នុងសហគមន៍ ដើម្បីការពារពីវិសមភាពទាក់ទងនឹងយេនឌ័រក្នុងការទទួលបានទឹកប្រើប្រាស់។ តាមរយៈការបញ្ជ្រាបការពិចារណាអំពីយេនឌ័រទៅក្នុងការគ្រប់គ្រងទឹក និងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងអាកាសធាតុនៅអនុតំបន់សាហារ៉ាអាហ្វ្រិកអាចឆ្ពោះទៅរកលទ្ធផលអភិវឌ្ឍន៍ប្រកបដោយសមធម៌ និង និរន្តរភាពបន្ថែមទៀត។

### ការពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ចអាចជួយឱ្យសម្រេចបាននូវសមភាពក្នុងការទទួលបានធនធានទឹក និងសេវា (WASH)

គម្រោងទឹកជាច្រើននៅក្នុងតំបន់គឺខ្វះថវិកា ហើយមានតម្រូវការសម្រាប់ការបង្កើនការវិនិយោគ ដើម្បីគាំទ្រគំនិតផ្តួចផ្តើមដែលឆ្លើយតបនឹងយេនឌ័រ។ ការផ្តល់ហិរញ្ញប្បទានប្រកបដោយបរិយាបន្ន និងឆ្លើយតបយេនឌ័រ អាចជួយដោះស្រាយបញ្ហាប្រឈមនឹងទឹកនៃអនុតំបន់សាហារ៉ា អាហ្វ្រិក។ ការប្រើប្រាស់បច្ចេកវិទ្យាប្រាក់ចល័ត សម្រាប់ការប្រមូលមូលនិធិ ជំរុញភាពជាដៃគូសាធារណៈ និងឯកជន និងការអនុវត្តយុទ្ធសាស្ត្រទីផ្សារ និងផ្តោតលើគោលដៅ គឺជាធាតុសំខាន់ក្នុងការកសាងទំនុកចិត្ត និងទាក់ទាញការវិនិយោគសំខាន់ៗ ដើម្បីបង្កើន ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទឹក។

ការផ្តល់ហិរញ្ញប្បទានដែលឆ្លើយតបនឹងយេនឌ័រអាចជំរុញការច្នៃប្រឌិតក្នុងវិស័យទឹក ដោយការលើកទឹកចិត្តដល់ការអភិវឌ្ឍន៍នៃដំណោះស្រាយដែលឆ្លើយតបនឹងតម្រូវការជាក់លាក់របស់ស្ត្រី និងក្រុមជនងាយរងគ្រោះ។ នេះទាមទារឱ្យមានកិច្ចសហការរវាងរដ្ឋាភិបាល អង្គការអន្តរជាតិ និងអ្នកពាក់ព័ន្ធក្នុងវិស័យឯកជន ដើម្បីប្រមូល ធនធាន និងធានាថាយន្តការហិរញ្ញប្បទានមានលក្ខណៈបរិយាបន្ន និងសមធម៌នៅក្នុងអនុតំបន់សាហារ៉ា អាហ្វ្រិក។

## តំបន់អាស៊ី និងប៉ាស៊ីហ្វិក

ទោះបីជាជវភាពយេនឌ័រមានលក្ខណៈខុសប្លែកគ្នាពីបរិបទមួយទៅបរិបទមួយក៏ដោយ ក៏ស្ត្រី និងក្មេងស្រីមានតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងធនធានទឹកសម្រាប់គ្រួសារ និងធនធានទឹកសម្រាប់ដំណើការផលិតផ្សេងៗ។ ទោះបីយ៉ាងណា ស្ត្រី និងក្មេងស្រី ប្រឈមមុខនឹងបញ្ហា ទឹកផ្អែកលើយេនឌ័រនៅទូទាំងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ បញ្ហាប្រឈមទាំងនេះរួមមាន៖ ការទទួលបានទឹកនៅមានកម្រិត និងពុំមានសមភាព ហានិភ័យចំពោះសុខភាព សុវត្ថិភាព ការអប់រំ ឱកាសសេដ្ឋកិច្ច និងកម្រិតជីវភាព ការមានតំណាងមិនគ្រប់គ្រាន់នៅក្នុងការគ្រប់គ្រងទឹក និងការគំរាមកំហែងកាន់តែខ្លាំងពីការប្រែប្រួលអាកាសធាតុ។

មានការសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងវិស័យទឹក និងអនាម័យ នៅក្នុងតំបន់ទាំងមូល។ ទោះបីយ៉ាងណា នៅតែមានបញ្ហាប្រឈមនៅក្នុងតំបន់ជនបទ និងតំបន់សំណង់មិនរៀបរយ ដែលបង្កផលប៉ះពាល់ខ្លាំងចំពោះស្ត្រី និងក្មេងស្រី។ ភស្តុតាងបានបង្ហាញថា ការបញ្ជ្រាបយេនឌ័រ និងការដាក់បញ្ចូលស្ត្រីទៅក្នុងគម្រោង និងគោលនយោបាយផ្គត់ផ្គង់ទឹក អាចលើកកម្ពស់ប្រសិទ្ធភាព ចីរភាព និងការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌។

ស្ត្រី៖ ដែលរួមមានស្ត្រីមកពីសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន មានឯកទេស និងចំណេះដឹងប្រពៃណី ក៏ដូចជាបទពិសោធន៍ គំនិត និងសំឡេងដាច់ដោយឡែក ដែលមានសារៈសំខាន់នៅក្នុងការកំណត់គោលនយោបាយ កម្មវិធី ការបែងចែកហិរញ្ញប្បទានសម្រាប់វិស័យធនធានទឹក និងកិច្ចសន្ទនាអន្តរជាតិ។

ការធានាឱ្យមានសមភាពយេនឌ័រនៅក្នុងការទទួលបានអភិបាលកិច្ច និងការគ្រប់គ្រងទឹក គឺពាក់ព័ន្ធនឹងយុត្តិធម៌សង្គម ហើយក៏ជាបុរេលក្ខខណ្ឌសម្រាប់ធានាឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព និងភាពធន់នឹងអាកាសធាតុផងដែរ។ ការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងយេនឌ័រ និងទឹកនៅអាស៊ី និងប៉ាស៊ីហ្វិក តម្រូវឱ្យមានការផ្លាស់ប្តូរដ៏ធំនៅក្នុងផ្នត់គំនិត បទដ្ឋានសង្គម ទិន្នន័យ គោលនយោបាយ និងការវិនិយោគ។ ឧទាហរណ៍ពី តំបន់ទាំងមូលបង្ហាញអំពីវិធីដែលអ្នករៀបចំគោលនយោបាយ និងអ្នកអនុវត្តអាចពង្រឹងអភិបាលកិច្ចទឹក តាមរយៈការធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រឆ្លើយតបចំពោះបញ្ហាយេនឌ័រ ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយបរិយាបន្ន និងកិច្ចអន្តរាគមន៍ចំគោលដៅដែលទទួលស្គាល់នូវតួនាទីសំខាន់ៗរបស់ស្ត្រី និងក្មេងស្រីក្នុងនាមជា ភ្នាក់ងារនៃការផ្លាស់ប្តូរ។

## អាមេរិកឡាទីន និងការាប៊ីន

ទឹកមានសារៈសំខាន់សម្រាប់ការងារក្នុងគ្រួសារ និងការងារថៃទាំ។ នៅអាមេរិកឡាទីន និងតំបន់ការាប៊ីន ទំនួលខុសត្រូវទាំងនេះភាគច្រើនធ្លាក់លើស្ត្រី ហើយជាធម្មតាមិនមានប្រាក់ខែ និងមិនត្រូវបានទទួលស្គាល់។

ការបញ្ជ្រាបសមភាពយេនឌ័រទៅក្នុងគោលនយោបាយទឹកនៅអាមេរិកឡាទីន និងតំបន់ការាប៊ីន អាចធ្វើទៅ បាន និងផ្លាស់ប្តូរ។ ទោះយ៉ាងណាក៏ដោយ វាកំពុងវិវត្តន៍ក្នុងអត្រាយឺត មិនទាន់បានពង្រឹងបន្ថែមឱ្យបានគ្រប់គ្រាន់ទេ។ ស្ត្រីជាពិសេសអ្នកដែលរស់នៅក្នុងសហគមន៍ជនបទ និងជនជាតិដើមភាគតិច ដើរតួយ៉ាង សំខាន់ ប៉ុន្តែជារឿយៗមិនត្រូវបានទទួលស្គាល់ក្នុងការទទួលបានទឹក ការគ្រប់គ្រង និងការគ្រប់គ្រងបរិស្ថាន។ នៅពេលដែលត្រូវបានគាំទ្រតាមរយៈគោលនយោបាយ និងកម្មវិធីបរិយាបន្ន ភាពជាអ្នកដឹកនាំរបស់ស្ត្រី អាចរួមចំណែកដល់ការគ្រប់គ្រងទឹកប្រកបដោយសមធម៌ និងនិរន្តរភាពបន្ថែមទៀត។

យ៉ាងណាក៏ដោយ ឧបសគ្គជាប្រព័ន្ធនៅតែមាន។ ការទទួលបានសេវាកម្មទឹកស្អាត និងអនាម័យ ប្រកបដោយសុវត្ថិភាព ភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លី និងធនធានមិនស្មើគ្នា និងភាពជាតំណាងរបស់ស្ត្រី ដែលមិនមានតួនាទីក្នុងការសម្រេចចិត្តបន្តពង្រឹងវិសមភាពយេនឌ័រ នៅមានកម្រិត។ បន្ទុកនៃការងារទាក់ទងនឹងទឹក ដែលមិនបានទទួលប្រាក់ឈ្នួលជាពិសេសរឹតត្បិតឱកាសរបស់ស្ត្រីក្នុងការទទួលបានការអប់រំ ការងារ និងការចូលរួមក្នុងសហគមន៍។

មានគំនិតផ្តួចផ្តើមក្នុងការឆ្លើយតប។ គំនិតផ្តួចផ្តើមទាំងនេះអាចបន្តអនុវត្តបាន ដោយពិចារណាលើបរិបទ ក្នុងតំបន់ផ្សេងៗគ្នា ហើយអាចពង្រីកបន្ថែម និងបទបែនតាមតំបន់។ ការទទួលស្គាល់ និងការរួមបញ្ចូល ចំណេះដឹងពីដូនតា និងពីមូលដ្ឋាន ជាពិសេសសហគមន៍ជនជាតិដើមភាគតិច គឺជាកត្តាសំខាន់សម្រាប់ការ អភិវឌ្ឍគោលនយោបាយទឹកដែលពាក់ព័ន្ធ និងមាននិរន្តរភាព។

ការសម្រេចបានសមភាពយេនឌ័រក្នុងអភិបាលកិច្ចទឹកតម្រូវឱ្យមានការផ្លាស់ប្តូរជាប្រព័ន្ធ៖ ការវិនិយោគលើ ទិន្នន័យបែងចែកតាមភេទ ការដកចេញនូវឧបសគ្គរបស់ស្ថាប័ន ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទឹកជនបទ និងការដាក់បញ្ចូលស្ត្រីកាន់តែច្រើនក្នុងការគ្រប់គ្រងទឹក និងវិស័យពាក់ព័ន្ធផ្សេងទៀត ដូចជាដីធ្លី និង បច្ចេកវិទ្យា។ កិច្ចខិតខំប្រឹងប្រែងទាំងនេះមានសារៈសំខាន់សម្រាប់យុត្តិធម៌សង្គម និងសម្រាប់ការកសាង សហគមន៍ដែលមានភាពធន់ និងសុវត្ថិភាពទឹកនៅទូទាំងតំបន់។

## អឺរ៉ុប

ទោះបីជាអឺរ៉ុបសម្រេចបានការគ្របដណ្តប់ស្ទើរតែជាសាកលក្នុងការទទួលបានការផ្គត់ផ្គង់ទឹក និងអនាម័យ ក៏ដោយ ក៏វិសមភាពយេនឌ័រនៅតែបង្កប់នៅក្នុងទិដ្ឋភាពជាច្រើននៃវិស័យទឹក។ ស្ត្រីនៅតែមិនទាន់មានភាពជាតំណាងនៅក្នុងតួនាទីបច្ចេកទេស ការគ្រប់គ្រង និងការបង្កើតគោលនយោបាយនៅក្នុងវិស័យទឹក បើទោះបី ជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ផ្នែកសមភាពយេនឌ័រនៅទូទាំងស្ថាប័នអឺរ៉ុបក៏ដោយ។ ឧបសគ្គខាងរចនាសម្ព័ន្ធមានដូចជា កង្វះការបង្ហាត់បង្ហាញ ការរំពឹងទុកនៃការទទួលបានការងារតាមយេនឌ័រ និងអតុល្យភាព ការងារនិងជីវិត អាចរួមចំណែកដល់វឌ្ឍនភាពរបស់ស្ត្រី និងការបន្តលើកកម្ពស់សមភាពយេនឌ័រទៅមុខនៅមានកម្រិត។

វិសមភាពយេនឌ័របែបនេះ មិនមែនគ្រាន់តែជាលទ្ធផលនៃគម្លាតបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែវាកើតចេញពីការដែលត្រូវបានគេមើលរំលងរបស់ស្ថាប័ន និងវប្បធម៌សង្គមដែលចាក់ឫសយ៉ាងជ្រៅ អំពីទស្សនទាននៃប្រព័ន្ធគ្រប់គ្រងទឹកត្រូវបានបង្កើត គ្រប់គ្រង និងផ្តល់ហិរញ្ញប្បទាន។ តួនាទីរបស់ស្ត្រីក្នុងការងារទាក់ទងនឹងទឹក ជាពិសេសនៅក្នុងបរិបទក្នុងតំបន់ និងការងារការថែទាំ ត្រូវបានគេឱ្យតម្លៃទាប ហើយភាគច្រើនមិនត្រូវបានគេមើលឃើញក្នុងការរៀបចំផែនការនិងថវិកាសម្រាប់គ្រប់គ្រងទឹក ។

ការផ្លាស់ប្តូរអំពីរបៀបដែលអភិបាលកិច្ចទឹក ដោយសមាហរន្តកម្មការវិភាគយេនឌ័រ អាចរួមចំណែកក្នុងការ ដោះស្រាយឧបសគ្គទាំងនេះ។ ស្ថាប័ននានាអាចប្រមូល និងប្រើប្រាស់ទិន្នន័យដែលបែងចែកភេទ ដោយជាប់លាប់ ក្នុងការរៀបចំការអនុវត្ត និងការត្រួតពិនិត្យគោលនយោបាយទឹក។ ការឱ្យតម្លៃលើការងារថែទាំ ដែលមិនបានទទួលប្រាក់ឈ្នួលនិងកម្លាំងពលកម្មក្នុងស្រុកនៅក្នុងប្រព័ន្ធផ្តល់សេវាទឹក និងក្របខណ្ឌតម្លៃ អាចជួយឱ្យមានការទទួលស្គាល់ការរួមចំណែកផ្នែកសេដ្ឋកិច្ចពេញលេញរបស់ស្ត្រី ចំពោះការគ្រប់គ្រងទឹក។

តាមរយៈការឆ្លុះបញ្ចាំងពីភាពជាក់ស្តែងអន្តរប្រសព្វនៃភេទ អាយុ ជាតិសាសន៍ និងស្ថានភាពសេដ្ឋកិច្ច ដែលរួមគ្នាកំណត់កម្រិតនៃភាពងាយរងគ្រោះចំពោះគ្រោះថ្នាក់ដែលទាក់ទងនឹងទឹក ការធ្វើការវាយតម្លៃ ហានិភ័យអាចជួយដល់ការលើកកម្ពស់បរិយាបន្ន។ ការអនុវត្តឧបករណ៍រៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រ នៅកម្រិតជាតិ និងអឺរ៉ុបអាចជំរុញការវិនិយោគលើវិស័យទឹក ដើម្បីលើក កម្ពស់ប្រសិទ្ធភាពបច្ចេកទេស សមភាព សង្គម និងនិរន្តរភាពរយៈពេលវែង។

## តំបន់អារ៉ាប់

តំបន់អារ៉ាប់ជាតំបន់មួយក្នុងចំណោមតំបន់ខ្វះខាតទឹកបំផុតក្នុងពិភពលោក។ វិបត្តិបន្ថែមអាចធ្វើឱ្យបញ្ហា ប្រឈមនឹងទឹកក្នុងតំបន់កាន់តែធ្ងន់ធ្ងរ រួមទាំងការប្រែប្រួលអាកាសធាតុ ជម្លោះ និងសេដ្ឋកិច្ចសង្គម និង ចលាចលនយោបាយ។ ស្ត្រី និងកុមារី ជារឿយៗទទួលបន្ទុកមិនសមហេតុផលនៃផលប៉ះពាល់ទាំងនេះ ដោយសារគំរូដែលទាក់ទងនឹងតួនាទីយេនឌ័រជាលក្ខណៈប្រពៃណី។

**ការឱ្យតម្លៃលើការថែទាំដែលមិនបានទទួលប្រាក់ឈ្នួល និងកម្លាំងពលកម្មក្នុងស្រុកនៅក្នុងប្រព័ន្ធផ្តល់សេវាទឹក និងក្របខ័ណ្ឌតម្លៃអាចជួយឱ្យទទួលស្គាល់ការរួមចំណែកសេដ្ឋកិច្ចពេញលេញរបស់ស្ត្រីចំពោះការគ្រប់គ្រងទឹក**

ខណៈពេលដែលមានការជឿនលឿនខ្លះនៅក្នុងការដាក់បញ្ចូលស្ត្រីក្នុងការគ្រប់គ្រងធនធានទឹក ចាំបាច់ត្រូវមាន បន្តធ្វើបន្ថែមទៀត។ ការអប់រំ និងការបណ្តុះបណ្តាលអាចជួយផ្តល់ចំណេះដឹង និងជំនាញចាំបាច់ដល់ស្ត្រី និងកុមារី ដើម្បីបង្កើតផលជះ។ ឧបសគ្គដែលកើតមានជាទូទៅគឺអត្ថិភាពនៃទម្រង់យេនឌ័រ ដែលអាចរារាំងដល់ ការចុះឈ្មោះរបស់ស្ត្រីក្នុងការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងការចូលរួម របស់ពួកគេក្នុងមុខតំណែងគ្រប់គ្រងទឹក។

គោលនយោបាយបញ្ជ្រាបយេនឌ័រក៏អាចជួយគាំទ្រដល់ការបញ្ចូលស្ត្រីក្នុងវិស័យទឹកនៅថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិផងដែរ។ អន្តរាគមន៍ជាច្រើនអាចត្រូវបានប្រើដើម្បីជំនះលើបញ្ហានេះ រួមទាំងការអនុវត្តការជួលប្រកប ដោយសមធម៌ និងកម្មវិធីដែលបង្កើនឥទ្ធិពលរបស់ស្ត្រីក្នុងការគ្រប់គ្រងទឹក។

យន្តការតាមដាន និងរាយការណ៍ដ៏រឹងមាំ រួមជាមួយនឹងការចែករំលែកការអនុវត្តល្អ រឿងជោគជ័យ និងមេរៀន ដែលបានរៀន តម្រង់ទិសគំនិតផ្តួចផ្តើមនាពេលអនាគតលើស្ត្រីដែលដឹកនាំវិស័យគ្រប់គ្រងទឹក ទឹកស្អាត និងអនាម័យ និង

ចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ខណៈពេលដែលលុបបំបាត់ផ្នត់គំនិតដែលអាចរារាំង ការចូលរួមរបស់ស្ត្រី។

ទោះបីការបណ្តុះបណ្តាល និងការកសាងសមត្ថភាពអាចជួយពង្រឹងស្ត្រីក៏ដោយ ក៏ត្រូវការគោលនយោបាយ ជាតិដើម្បីបម្លែងការអប់រំទៅជាសកម្មភាពជាក់ស្តែងផងដែរ។

## ទិន្នន័យ ការអប់រំ និងការអភិវឌ្ឍសមត្ថភាព

សមភាពយេនឌ័រនៅក្នុងការទទួលបាន និងការគ្រប់គ្រងទឹក ទិន្នន័យអំពីវឌ្ឍនភាពនៅក្នុងសមភាពយេនឌ័រ ព្រមទាំងការអប់រំ និងការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធដែលមានភាពចាំបាច់ដើម្បីធានាឱ្យមានសមភាព មានសារៈសំខាន់សម្រាប់ការកែលម្អការរស់នៅរបស់ស្ត្រី និងបុរស និងដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ក្រៅពីវិស័យទឹក។

ការស្នើឱ្យមានទិន្នន័យបែងចែកតាមភេទនៅក្នុងពិភពទឹក មិនមែនជារឿងថ្មីឡើយ។ ទិន្នន័យដែលមានការបែងចែកត្រូវបានប្រមូលជាទៀងទាត់នៅក្នុងវិស័យផ្សេងទៀត ប៉ុន្តែវិធីសាស្ត្រទទួលស្គាល់ពេលវេលាដែលគេមិនសូវឱ្យតម្លៃរបស់ស្ត្រី ទោះបីជាមាន ក៏នៅតែគ្មានការប្រើប្រាស់គ្រប់គ្រាន់នៅឡើយ។ នៅក្នុងទិដ្ឋភាពដ៏ល្អបំផុត ចន្លោះខ្វះខាតនៃទិន្នន័យយេនឌ័រគឺជាការបាត់បង់ឱកាសនៅក្នុងការកាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងវិស័យទឹក។ នៅក្នុងទិដ្ឋភាពដ៏អាក្រក់បំផុត ចន្លោះខ្វះខាតនៃទិន្នន័យយេនឌ័រធ្វើឱ្យពលកម្ម "មិនទទួលបានប្រាក់" របស់ស្ត្រីមិនទទួលបានការឱ្យតម្លៃពីសហគមន៍ និងអ្នកស្រាវជ្រាវ ម្ចាស់ជំនួយ និងអ្នករៀបចំគោលនយោបាយដែលនៅតែបន្តរៀបចំ និងផ្សព្វផ្សាយបច្ចេកវិទ្យាទឹកដែលត្រូវបានកំណត់ដោយមិនត្រឹមត្រូវថា "មានតម្លៃទាប" នៅពេលគិតថ្លៃពលកម្មដែលកើតឡើងរួមគ្នានៅក្នុងការអនុវត្តជាក់ស្តែងតាមពិតទាំងនេះគឺជាបច្ចេកវិទ្យាទឹក "ដែលមានតម្លៃខ្ពស់»។

ការអភិវឌ្ឍជំនាញ និងសមត្ថភាពក្នុងប្រទេស ដើម្បីតាមដាន និងវាយតម្លៃកម្មវិធីទឹកតាមរយៈការយល់ឃើញចំពោះយេនឌ័រ គឺមានសារៈសំខាន់ដើម្បីធានាឱ្យមានការគ្រប់គ្រងទឹកកាន់តែមានសមធម៌ និងមានប្រសិទ្ធភាព។ ការបណ្តុះបណ្តាលស្ត្រី តាមរយៈឱកាសចូលរួមកាន់តែមានសមភាពនៅក្នុង STEM និងឱកាសការងារ អាចធ្វើឱ្យស្ត្រីក្លាយជាភាគីពាក់ព័ន្ធ និងជាអ្នកដឹកនាំក្នុងការបង្កើតចំណេះដឹង និងនៅក្នុងការសម្រេចចិត្តគ្រប់គ្រងទឹកនៅគ្រប់កម្រិត។ ការអភិវឌ្ឍជំនាញ (និងចេញវិញ្ញាបនបត្រទទួលស្គាល់) មានភាពចាំបាច់ ដើម្បីដោះស្រាយ ការតំណាងលើសកម្រិតរបស់ស្ត្រីនាពេលបច្ចុប្បន្ន នៅក្នុងការងារទឹកដែលមានតម្លៃទាប និងផ្តល់ប្រាក់កម្រៃទាប និងការមានតំណាងមិនគ្រប់គ្រាន់នៅក្នុងការសម្រេចចិត្ត និងមុខតំណែងដែលទទួលបានប្រាក់កម្រៃខ្ពស់។

ជាទំនៀមទម្លាប់ រដ្ឋគឺជាអ្នកទទួលខុសត្រូវចម្បងនៅក្នុងតួនាទីអភិវឌ្ឍន៍សមត្ថភាពនេះ ប៉ុន្តែអាចត្រូវការការគាំទ្រផ្នែកបច្ចេកទេស ការគាំទ្រលើការគ្រប់គ្រង និងផ្នែកហិរញ្ញវត្ថុដ៏ច្រើនពីវិស័យឯកជន និងភាពជាដៃគូសង្គមស៊ីវិល។ ហិរញ្ញវត្ថុផ្ទៃក្នុង និងផ្ទៃក្រៅ ដែលផ្អែកលើគោលការណ៍ចីរភាព និងសមភាពនៅក្នុងការទទួលបាន និងការគ្រប់គ្រង អាចជួយត្រួសត្រាយផ្លូវឱ្យកាន់តែមានភាពរលូនឆ្ពោះទៅវិស័យទឹកដែលកាន់តែមានសមធម៌ និងមានប្រសិទ្ធភាព។

## អភិបាលកិច្ច

ក្របខណ្ឌបទដ្ឋានអន្តរជាតិ និងសិទ្ធិមនុស្សបានកែសម្រួលតាមបរិបទនូវសារៈសំខាន់ចម្បងនៃអភិបាលកិច្ចទឹក។ អភិបាលកិច្ចធនធានទឹក ការទទួលបាន ការបែងចែក សេវា និងការផ្គត់ផ្គង់ទឹកមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើសិទ្ធិភាពធន់ ជីវភាព សុខភាព និងសុខុមាលភាពរបស់ប្រជាជន និងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពទាំងមូល។ នេះជារឿងពិតសម្រាប់ស្ត្រី ក្មេងស្រី និងប្រជាជនដែលមានភេទខុសៗគ្នា ព្រមទាំងសម្រាប់គ្រួសារ និងសហគមន៍របស់ពួកគាត់។

អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ មានការអំពាវនាវឱ្យមានការបញ្ជ្រាបយេនឌ័រទៅក្នុងការគ្រប់គ្រងទឹក និងការធ្វើសេចក្តីសម្រេចចិត្ត ដោយមានភស្តុតាងបង្ហាញថា ការចូលរួមរបស់ស្ត្រីមានសារៈសំខាន់ដើម្បីឱ្យការអនុវត្តគម្រោងទឹកមានប្រសិទ្ធភាព និងចីរភាព និង

លើកកម្ពស់ការគ្រប់គ្រងទឹកនៅតាមមូលដ្ឋាន។ ទោះបីយ៉ាងណា មានគម្លាតយេនឌ័រយ៉ាងខ្លាំងនៅក្នុងការគ្រប់គ្រងទឹក ការដឹកនាំ និងការគ្រប់គ្រងហិរញ្ញវត្ថុនៅកម្រិតថ្នាក់ជាតិ ក្រុង និងមូលដ្ឋាន នៅក្នុងរដ្ឋាភិបាល ក្រុមហ៊ុនផ្គត់ផ្គង់ទឹកសាធារណៈ និងឯកជន ព្រមទាំងការគ្រប់គ្រងទឹក និងក្រុមអ្នកប្រើប្រាស់។ សិទ្ធិរបស់ស្ត្រីក្នុងការទទួលបាន និងការគ្រប់គ្រងធនធានទឹក ព្រមទាំងការទទួលបាន និងទទួលប្រយោជន៍ពីទឹក ភាគច្រើននៅតែមិនទាន់សម្រេចបាននៅឡើយ។

នៅពេលដែលស្ត្រី និងយុវជនចូលរួមនៅក្នុងអភិបាលកិច្ចទឹក ជារឿយៗការចូលរួមនេះអាចត្រឹមតែជា "និមិត្តរូបប៉ុណ្ណោះ"។ អាចមានការដាក់បញ្ចូលដើម្បីតែបង្គ្រប់កិច្ច ឬដើម្បីជានិមិត្តរូបនៅក្នុងកិច្ចប្រជុំ និងការពិគ្រោះយោបល់ផ្សេងៗ និងការរាយការណ៍អំពីវត្តមានរបស់ស្ត្រី និងយុវជនដោយមិនបានពិចារណាទៅលើឧបសគ្គក្នុងការធ្វើដំណើរ ទំនួលខុសត្រូវលើការងារថែទាំគ្រួសារ និងការងារផ្ទះដែលមិនទទួលបានប្រាក់ ឬថាតើពួកគាត់បានចូលរួមយ៉ាងសកម្ម ឬមានឥទ្ធិពលលើការសម្រេចចិត្ត ឬគោលនយោបាយ ឬយ៉ាងណាឡើយ។

ការមិនឱ្យតម្លៃចំពោះពលកម្ម ចំណេះដឹង និងជំនាញរបស់ស្ត្រី និងផ្នត់គំនិតយេនឌ័រអំពីភាពស័ក្តិសមរបស់ស្ត្រីសម្រាប់ការងារមួយចំនួន ដែលរួមមានការធ្វើដំណើរ និងការងារនៅទីតាំងផ្ទាល់ គឺជាមូលដ្ឋានសម្រាប់ការបែងចែកការងារ និងគម្លាតប្រាក់ឈ្នួលផ្អែកលើយេនឌ័រ។

ការលើកកម្ពស់ឱ្យមានការចូលរួមពិតប្រាកដ និងមានប្រសិទ្ធភាពរបស់ស្ត្រី និងក្មេងស្រីនៅក្នុងការគ្រប់គ្រងទឹក អាចសម្រេចបានតាមរយៈការអនុម័តកំណែទម្រង់ច្បាប់ និងការអនុវត្តគោលនយោបាយដែលផ្តល់ការគាំទ្រការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិដើម្បីជំទាស់នឹងការរើសអើង និងការមិនរាប់បញ្ចូល ព្រមទាំងកសាងសមត្ថភាពរបស់ភាគីពាក់ព័ន្ធ ដើម្បីមានឥទ្ធិពលប្រកបដោយដោយចំណេះដឹងទៅលើការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំគោលនយោបាយនៅកម្រិតមូលដ្ឋានកម្រិតថ្នាក់ជាតិ និងសកលលោក។

# ហិរញ្ញប្បទាន និងការវិនិយោគ

ការរៀបចំថវិកាដែលគិតគូរចំពោះយេនឌ័រ ចាំបាច់ត្រូវការការលើកទឹកចិត្តឱ្យបានខ្លាំងក្លា និងគាំទ្រដោយយន្តការគណនេយ្យភាពច្បាស់លាស់ និងមានតម្លាភាពពេញលេញ។ តាមរយៈបទពិសោធន៍បានបង្ហាញឱ្យឃើញថា វិធីសាស្ត្រតាមបែបស្ម័គ្រចិត្ត ឬពិសេស តែងតែមិនអាចសម្រេចទៅបាន ដែលជារឿយៗបណ្តាលឱ្យមានការបែងចែកត្រឹមតែជានិមិត្តរូប និងការវិនិយោគតិចតួច និងគ្មានចីរភាព។ ទោះបីយ៉ាងណា មានភស្តុតាងបង្ហាញថា ការដាក់បញ្ចូលស្ត្រី និងក្មេងស្រីទៅក្នុងដំណើរការទាំងនេះអាចបង្កើនការចំណេញផ្នែកហិរញ្ញវត្ថុ តាមរយៈការពង្រឹងការធ្វើសេចក្តីសម្រេចចិត្ត ធ្វើឱ្យប្រសើរឡើងនូវការទទួលយកចាប់ពីថ្នាក់ក្រោមឡើងទៅលើ និងបង្កើនប្រសិទ្ធភាពគម្រោង។

## មានគម្លាតយេនឌ័រយ៉ាងខ្លាំងនៅក្នុងការគ្រប់គ្រងទឹក ការដឹកនាំ និងការគ្រប់គ្រងហិរញ្ញវត្ថុ

ការរៀបចំការវាយតម្លៃហួសពីការគណនាប្រាក់ចំណេញហិរញ្ញវត្ថុធម្មតា និងជំនួសមកវិញដោយការវាយតម្លៃសេដ្ឋកិច្ច-សង្គមរយៈពេលវែងជាងមុន និងកាន់តែទូលំទូលាយ អាចជួយឱ្យយុទ្ធសាស្ត្រហិរញ្ញវត្ថុគិតគូរអំពីតួនាទីសំខាន់ៗ ប៉ុន្តែតែងតែមិនត្រូវបានផ្តល់តម្លៃរបស់ស្ត្រី និងក្មេងស្រីនៅក្នុងប្រព័ន្ធទឹក។ ការវាយតម្លៃទាំងនេះអាចមាននូវធាតុផ្សំមួយចំនួន (ឧទាហរណ៍ ការងារផ្ទះពាក់ព័ន្ធនឹងទឹកដែលមិនទទួលបានប្រាក់ ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់) ដែលត្រូវបានទទួលស្គាល់នៅក្នុងយុទ្ធសាស្ត្រហិរញ្ញប្បទាន។ ការវាយតម្លៃផលប៉ះពាល់ និងតម្លៃជាបន្តបន្ទាប់រយៈពេលវែងជាការងារលំបាក ប៉ុន្តែមានសារៈសំខាន់។

ការចូលរួមប្រកបដោយគុណប្រយោជន៍នៅក្នុងដំណើរការផ្តល់ហិរញ្ញប្បទានអាចពង្រឹងទំនុកចិត្ត តម្លាភាព និងភាពជាម្ចាស់របស់សហគមន៍ ដែលអាចធ្វើឱ្យប្រសើរឡើងនូវចីរភាពនៃការវិនិយោគ។ នីតិវិធី និងយុទ្ធសាស្ត្រច្បាស់លាស់ និងកែសម្រួលតាមស្ថានភាព គឺត្រូវការជាចាំបាច់ ដើម្បីដោះស្រាយឧបសគ្គផ្នែករចនាសម្ព័ន្ធ ដូចជាកម្មសិទ្ធិដីធ្លីមានកម្រិត ការទទួលបានសេវាធនាគារ និងប្រវត្តិឥណទាន

ដោយមិនធ្វើឱ្យជាប់នៅក្នុងអន្ទាក់បំណុល។ក្របខណ្ឌហិរញ្ញប្បទានឆ្លើយតបចំពោះយេនឌ័រអាចត្រូវបានកែលម្អតាមរយៈការដាក់បញ្ចូលវិធានការទទួលខុសត្រូវ និងប្រឆាំងអំពើពុករលួយដែលមានភាពច្បាស់លាស់។ ការបង្កើនតម្លាភាពនៅក្នុងលំហូរហិរញ្ញវត្ថុអាចការពារធនធានដោយធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសម្រាប់សមភាពយេនឌ័រនៅក្នុងការផ្តល់ហិរញ្ញប្បទានទឹក។ ជាងនេះទៅទៀត ការផ្តល់ហិរញ្ញប្បទានឆ្លើយតបចំពោះយេនឌ័រមិនត្រូវធ្វើឱ្យបន្ទុកបំណុលរបស់ប្រទេសកំពុងអភិវឌ្ឍន៍កាន់តែធ្ងន់ធ្ងរ នឹងបង្កើតឱ្យមានការពឹងផ្អែកផ្អែកហិរញ្ញវត្ថុថ្មី ដែលធ្វើឱ្យប៉ះពាល់ដល់វឌ្ឍនភាពឆ្ពោះទៅរកសមភាពយេនឌ័រនៅក្នុងវិស័យទឹកឡើយ។

# សេចក្តីថ្លែងបញ្ចប់

សមភាពយេនឌ័រមានសារៈសំខាន់នៅក្នុងការទទួលបានធនធានទឹក និងការបំពេញលក្ខខណ្ឌសិទ្ធិមនុស្សនៅក្នុងការទទួលបានទឹក និងសេវាអនាម័យ។

ទោះបីស្ត្រី និងក្មេងស្រីនៅតែមានទំនួលខុសត្រូវភាគច្រើនលើកិច្ចការពាក់ព័ន្ធនឹងទឹកនៅផ្ទះយ៉ាងណាក្តី ប៉ុន្តែពួកគាត់រងផលប៉ះពាល់ខ្លាំងដោយសារកង្វះខាតសេវាទឹកស្អាត និងអនាម័យនៅតាមសាលារៀន កន្លែងធ្វើការ មណ្ឌលថែទាំសុខភាព និងគ្រួសារ។

ជាទូទៅ ការទទួលបានធនធានទឹកមានទំនាក់ទំនងជាមួយនឹងការកាន់កាប់ដីធ្លី ដែលប៉ះពាល់ដោយផ្ទាល់ដល់ភាពអាចរកបាននៃទឹកសម្រាប់ប្រើប្រាស់នៅក្នុងដំណើរការផលិតកម្មដូចជាការធ្វើស្រែចម្ការ ដែលធ្វើឱ្យស្ត្រី និងបុរសមួយចំនួនជួបប្រទះនឹងឧបសគ្គផ្នែកសង្គម និងសេដ្ឋកិច្ច។

កង្វះទិន្នន័យទឹកបែងចែកតាមភេទនៅតែជាចំណុចមើលមិនឃើញជាមូលដ្ឋាន ដែលធ្វើឱ្យមានការលំបាកក្នុងការមើលឃើញវិសមភាពនៅក្នុងការទទួលបាន កម្លាំងពលកម្ម និងការធ្វើសេចក្តីសម្រេចចិត្ត។ ការដោះស្រាយចន្លោះខ្វះខាតនេះមានសារៈសំខាន់ដើម្បីឱ្យការអនុវត្តគោលនយោបាយ និងការវិនិយោគលើទឹកមានប្រសិទ្ធភាព និងគណនេយ្យភាព។

ជាទូទៅ ស្ត្រីមានតំណាងតិចតួចនៅក្នុងការងារ និងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងទឹកដែលធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ពួកគាត់ក្នុងការចូលរួមកែលម្អការអនុវត្តការគ្រប់គ្រងទឹក។ ទោះជាយ៉ាងនេះក្តី ស្ត្រីជាច្រើនដែលមានកម្រិតសេដ្ឋកិច្ចសង្គម កម្រិតវប្បធម៌ និងវិជ្ជាជីវៈផ្សេងៗគ្នាបានចូលរួមចំណែកនៅក្នុងការគ្រប់គ្រងទឹកអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ របាយការណ៍នេះផ្អែកទៅលើការងាររបស់ស្ត្រី ដោយគូសរំលេចនូវឧទាហរណ៍ដែលអាចមានប្រយោជន៍នៅក្នុងការលុបបំបាត់គម្លាតយេនឌ័រនៅក្នុងវិស័យទឹក។

ការដោះស្រាយវិសមភាពផ្អែកលើយេនឌ័រពាក់ព័ន្ធនឹងទឹកគឺជាចំណុចគន្លឹះនៅក្នុងការកាត់បន្ថយភាពក្រីក្រ ការបំពេញលក្ខខណ្ឌសិទ្ធិមនុស្សក្នុងការទទួលបានទឹក និងអនាម័យ និងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពភាគច្រើន។

នៅពេលនិយាយអំពីទឹក សមភាពយេនឌ័រនាំមកនូវឱកាសកាន់តែច្រើនសម្រាប់ទាំងអស់គ្នា។

បោះពុម្ពផ្សាយនៅឆ្នាំ2026 ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃអង្គការសហប្រជាជាតិ (United Nations Educational, Scientific and Cultural Organization)

អាសយដ្ឋានអគារលេខ 7, Place de Fontenoy, 75352 Paris 07 SP, ប្រទេសបារាំង

និង អង្គការអុកស្វាមប្រចាំប្រទេសកម្ពុជា អាសយដ្ឋានអគារ The Point, ជាន់ទី៣, បន្ទប់ U08-09, លេខ 113C មហាវិថីម៉ៅសេទុង, ទួលស្វាយព្រៃ I, បឹងកេងកង, រាជធានីភ្នំពេញ

SC-2026/WS/1

https://doi.org/10.54679/EIHQ9796

CC BY SA © អង្គការយូណេស្កូ និង អង្គការអុកស្វាមប្រចាំប្រទេសកម្ពុជា ឆ្នាំ2026

រៀបចំដោយអង្គការយូណេស្កូ WWAP | Richard Connor

ឯកសារបោះពុម្ពផ្សាយនេះផលិតដោយអង្គការ UNESCO WWAP តាងនាមអង្គការ UN-Water។

បកប្រែដោយ អង្គការអុកស្វាមប្រចាំប្រទេសកម្ពុជា

រចនាគម្របដោយ Anna Marie Manning Zylicz

រូបថតគម្រប៖ © Anna Marie Manning Zylicz

ការរចនាក្រាហ្វិក និងប្លង់ដោយ Marco Tonsini

សេចក្ដីសម្គាល់ដែលបានប្រើប្រាស់ និងការបង្ហាញអំពីឯកសារនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបញ្ជាក់អំពីការបញ្ចេញមតិណាមួយរបស់អង្គការយូណេស្កូពាក់ព័ន្ធនឹងទិដ្ឋភាពផ្លូវច្បាប់របស់ប្រទេស ទឹកដី ទីក្រុង ឬតំបន់ណាមួយ ឬអាជ្ញាធររបស់ប្រទេស ឬទឹកដីទាំងនោះ ឬពាក់ព័ន្ធនឹងការកំណត់ព្រំដែន ឬព្រំប្រទល់ណាមួយឡើយ។ គំនិត និងទស្សនៈដែលបានបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះគឺជារបស់អ្នកនិពន្ធ និងមិនសុទ្ធតែឆ្លុះបញ្ចាំងអំពីគំនិត និងទស្សនៈរបស់អង្គការយូណេស្កូឡើយ ហើយក៏មិនមែនជាការសន្យារបស់អង្គការនោះដែរ។

សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការរក្សាសិទ្ធិ និងការផ្ដល់អាជ្ញាប័ណ្ណ សូមមើលរបាយការណ៍ពេញលេញដែលមាននៅ www.unesco.org/en/wwap ។

កម្មវិធីវាយតម្លៃទឹកពិភពលោករបស់អង្គការយូណេស្កូ

ការិយាល័យកម្មវិធីសម្រាប់ការវាយតម្លៃទឹកសកល

ផ្នែកវិទ្យាសាស្ត្រទឹក អង្គការយូណេស្កូ

06134 Colombella, Perugia, ប្រទេសអ៊ីតាលី

អ៊ីមែល៖ wwap@unesco.org

www.unesco.org/en/wwap

unesco
World Water
Assessment Programme

OXFAM

យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់រដ្ឋាភិបាលអ៊ីតាលី និងអង្គការ Regione Umbria។

REPVBBLICA ITALIANA

Regione Umbria